# ពិធីប្រគល់បណ្ណសរសើរដល់និស្សិតឆ្នើម ឆ្នាំសិក្សា ២០១៤-២០១៥
# (Outstanding Award Academic Year 2014-2015)

*សាកលវិទ្យាល័យអន្តរជាតិ ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៦*



*(ឯកឧត្តម សាស្ត្រាចារ្យ មហាបរិញ្ញា បណ្ឌិត សាបូ អូហ្សាណូ និងលោកជំទាវ)*

ពិធីប្រគល់បណ្ណសរសើរដល់និស្សិតឆ្នើមប្រចាំឆ្នាំសិក្សា ២០១៤-២០១៥ (Outstanding Award) ដែលបានប្រារព្ធធ្វើនាថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៦ នៅសាកលវិទ្យាល័យអន្តរជាតិ ក្រោមអធិបតីភាពលោកជំទាវ **អ៊ុក វ៉ារីន** ប្រធានក្រុមប្រឹក្សាភិបាល នៃសាកលវិទ្យាល័យ អន្តរជាតិ និងឯកឧត្តម សាស្ត្រាចារ្យមហាបរិញ្ញា បណ្ឌិត **សាបូ អូហ្សាណូ** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យ អន្តរជាតិ និងមានជ័យលាភីនិស្សិតឆ្នើមប្រចាំឆ្នាំសិក្សា ២០១៤-២០១៥ ចំនួន ៤០៣នាក់។ ឯកឧត្តម បណ្ឌិត **នេត បារ៉ុម** សាកលវិទ្យាធិការរង នៃសាកលវិទ្យាល័យ អន្តរជាតិ បានថ្លែងថា ពិធីប្រគល់បណ្ណសរសើរដល់និស្សិតឆ្នើម ត្រូវបានសាកលវិទ្យាល័យ ប្រារព្ធធ្វើជារៀងរាល់ឆ្នាំ ដើម្បីជាផ្នែកមួយក្នុងការលើកទឹកចិត្តដល់និស្សិតដែលខិតខំព្យាយាមសិក្សា។



*(ទិដ្ឋភាពរួមក្នុងអង្គពិធី)*

ទន្ទឹមនឹងការសាទរលទ្ធផលជោគជ័យរបស់និស្សិតឆ្នើម ឯកឧត្តមបណ្ឌិត **នេត បារ៉ុម** បានចូលចែករំលែកបទពិសោធន៍ចំពោះនិស្សិតឆ្នើមថា នៅក្នុងបរិបទនេះ មានតែការអប់រំដែលប្រកបដោយគុណភាព ទើបជាកត្តាដ៏ចំបាច់បំផុតក្នុងការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ចប្រទេស។

ក្នុងពិធីដ៏វិសេសវិសាលនេះ ឯកឧត្តមសាកលវិទ្យាធិការរង បានជំរុញឲ្យនិស្សិតឆ្នើមទាំងអស់ត្រូវបន្តខិតខំព្យាយាមសិក្សាឲ្យរឹងរឹតតែខ្លាំងដើម្បីការពារតំណែងនេះឲ្យបានជាប់។ ក្រៅតែពីសោមនស្សចំពោះការរៀបចំពិធីប្រគល់បណ្ណសរសើរដល់និស្សិតឆ្នើមប្រចាំឆ្នាំសិក្សា ២០១៤-២០១៥ (Outstanding Award 2014-2015) ឯកឧត្តម បណ្ឌិត **ជា មុនីរិទ្ធិ** នាយកវិទ្យាស្ថានខុងជឺ នៃរាជ្យបណ្ឌិតសភាកម្ពុជាក៏បានចូលរួមចែករំលែកចំណេះដឹងទាក់ទងនឹងគោលនយោបាយ "ខ្សែក្រវាត់មួយ ផ្លូវមួយ" របស់រដ្ឋាភិបាលចិន។



*(និស្សិតឆ្នើមប្រចាំឆ្នាំសិក្សា ២០១៤-២០១៥)*

ឯកឧត្តម សាស្ត្រាចារ្យមហាបរិញ្ញា បណ្ឌិត **សាបូ អូហ្សាណូ** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យ អន្តរជាតិ បានបញ្ជាក់ពីមូលហេតុនៃការប្រារព្ធពិធីប្រគល់បណ្ណសរសើរដល់និស្សិតឆ្នើម នៅថ្ងៃទី១៤ ខែកុម្ភៈ គឺដើម្បីរំលឹកដល់ថ្ងៃកំណើតរបស់ ឯកឧត្តមសាស្ត្រាចារ្យ អ៊ូន សាបូ បិតាស្ថាបនិក សាកលវិទ្យាល័យ អន្តរជាតិ ក្នុងកិច្ចខិតខំប្រឹងប្រែងពុះពារគ្រប់ឧបសគ្គដើម្បីបង្កើតសាកលវិទ្យាល័យនេះ។ នៅទីបញ្ចប់ ឯកឧត្តម សាកលវិទ្យាធិការ បានចូលរួមសាទរចំពោះនិស្សិតឆ្នើមទាំង ៤០៣ នាក់ ក៏ដូចជាអាណាព្យាបាលរបស់និស្សិតឆ្នើម និងស្នើសុំឲ្យនិស្សិតឆ្នើមឆ្នាំសិក្សា ២០១៤-២០១៥ ទាំងអស់សូមបន្តខិតខំសិក្សាដើម្បីការពារខ្សែក្រវ៉ាត់របស់ខ្លួនសម្រាប់ឆ្នាំសិក្សាក្រោយៗ ទៀត។ ពិធីនេះត្រូវបានបិទបញ្ចប់នៅម៉ោង ១២:០០ នាទីថ្ងៃត្រង់ក្រោមបរិយាកាសសប្បាយរីករាយក្រៃលែង៕

*រៀបរៀងដោយលោក វួច ពិសិដ្ឋ ប្រធានការិយាល័យកិច្ចការអន្តរជាតិ*